អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ខូអាឡាដីឥដ្ឋ**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃនិងភ្នែកសាច់ដុំភ្នែក)។

**វិទ្យាសាស្ត្រ**

ការរស់នៅប្រចាំថ្ងៃ (ការស្វែងយល់ដោយការសង្កេត)

**សិក្សាសង្គម**

គំនូរនិងសកម្មភាពកសាង (ការយល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព)

**គោលបំណង** ៖

**(ចិត្តចលភាព)** ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬ លេងល្បែង។

**(វិទ្យាសាស្ត្រ)** ប្រាប់បានពីឈ្មោះសត្វផ្សេងៗ រៀបរាប់ឈ្មោះសត្វ ចរិកលក្ខណៈ លក្ខខណ្ឌរស់នៅ វដ្តនៃសត្វ ការប្រៀបធៀបនៃសត្វ និងផលប្រយោជន៍។

**(សិក្សាសង្គម)** ប្រាប់បានពីរបៀបសូនរូប គូររូប ផាត់ពណ៌ដើម្បីបង្កើតបានជារូបភាពផ្សេងៗ។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ រៀបចំបង្កើតដីឥដ្ឋ ឬមានស្រាប់ក៏បានឱ្យគ្រប់ចំនួនសិស្សនៅក្នុងថ្នាក់របស់អ្នក

- ដីឥដ្ឋដែលមាន៣ពណ៌ផ្សេងគ្នា
- ក្រដាសសម្រាប់ក្មេងៗទាំងអស់
- គ្រាប់សណ្តែកខ្មៅតូចៗ សម្រាប់ធ្វើជាគ្រាប់ភ្នែក (ម្នាក់២គ្រាប់)

**ការរៀបចំ** ៖ ធ្វើដីឥដ្ឋដែលមាន ៣ពណ៌ ចែកដីឥដ្ឋជាដុំៗនិងឱ្យទៅពួកគេម្នាក់១ដុំ។ អនុវត្តធ្វើជាសត្វខូអាឡា។ ដីឥដ្ឋត្រូវនៅពីមុខអ្នកធ្វើសត្វខូអាឡាទាំងអស់ជាមុនសិន មុននឹងឱ្យពួកគេធ្វើដោយខ្លួនឯង ក៏បានមិនបង្ហាញក៏បានដែរ ទៅតាមការជាក់ស្តែងរបស់កុមារ។

**សេចក្តីណែនាំ៖**

1. ថ្ងៃនេះអ្នកគ្រូនឹងលេងល្បែង**ខូអាឡាដីឥដ្ឋជាមួយកូនៗ** ទាំងអស់គ្នា។
2. សួរក្មេងៗ៖ តើកូនៗស្គាល់ខេទីដែលជាសត្វខូអាឡាដែរឬទេ? បាទ/ចាស ស្គាល់
   យកសត្វខូអាឡាដីឥដ្ឋមកបង្ហាញជាមួយនឹងដីឥដ្ឋដែរ។
3. បង្ហាញក្មេងៗពីរបៀបលេងដីឥដ្ឋ។ បង្ហាញអ្វីដែលកើតឡើងនៅពេលវាប្រចាប់ខ្លាំងពេក ឬតិចពេក (វាស្អិតនឹងពិបាកលេង) ។

4. ផ្តល់ឱ្យកូនៗនូវក្រដាសមួយសន្លឹក ដីឥដ្ឋ ៣ដុំ សណ្តែកខ្មៅ ២គ្រាប់។
5. បង្ហាញពីរបៀបបង្កើតសត្វខូអាឡាដែលមានជំហានដូចនេះ៖
    - បន្ទាប់ពីបានចែកឱ្យកុមារម្នាក់ៗរួច
    - ដំបូងប្រើដីឥដ្ឋពណ៌ប្រផេះសម្រាប់ធ្វើជាក្បាលរបស់វា
    - បន្ទាប់មកយកដីឥដ្ឋពណ៌ទឹកក្រូចសម្រាប់ធ្វើជាច្រមុះ
    - គ្រាប់សណ្តែកខ្មៅបិទធ្វើជាភ្នែករបស់វា
    - ដីឥដ្ឋពណ៌ប្រផេះបន្តធ្វើជាត្រចៀករបស់វាទាំងសងខាង និងដីឥដ្ឋពណ៌សបិទពីលើត្រចៀករបស់វាទាំងសងខាងដែរ
    - នៅពេលរួចរាល់ផ្នែកមុខហើយ ធ្វើខ្លួនរបស់វាម្តង ទៅតាមរូបដែលបានបង្ហាញនៅក្នុងវីដេអូឬក្រដាសសន្លឹកកិច្ចការ។
6. សុំឱ្យក្មេងៗធ្វើសត្វខូអាឡាផ្ទាល់ខ្លួនដោយយកគំរូតាមអ្នកដែលបានធ្វើរួច និងឱ្យគាត់មើលវីដេអូដែលមានស្រាប់ក្នុងគេហទំព័រ Rermork.org នេះបាន។
7. នៅពេលដែលកុមារទាំងអស់កំពុងធ្វើជារូបសត្វខូអាឡានោះ គ្រូត្រូវដើរពិនិត្យពួកគេ ដើម្បីជួយប្រាប់ប្រសិនបើពួកគាត់ត្រូវការជំនួយផងដែរ។